Monthly Report
Volume 43

July
2025

**Project Activities in July:**

- 30th Jun.–7th Jul.: Conducting Online Post Training Evaluation
- 10th : Monthly Meeting with JICA HQ / Cambodia Office
- 16th : 6th JCC Meeting
- 31st : Orientation Meeting for PTMT in BTB

## 6th Joint Coordination Committee Meeting at the Ministry of Health

On 16 July 2025, the 6th Joint Coordination Committee (JCC) Meeting of the STRINGS Project was held by the Ministry of Health (MoH), in collaboration with JICA. The meeting was chaired by H.E. Prof. THIR Kruy, Secretary of State of the MoH and Project Director, and attended by key stakeholders, including representatives from the MoH, JICA, the Embassy of Japan, and other relevant organizations.

The meeting provided a valuable opportunity to review the progress made between December 2024 and June 2025, and to discuss the activity plan for the second half of the year. Assit. Prof. TOUCH Sokneang, the director of Human Recourse Development Department of the MoH, and the Project Manager, presented an overview of the implementation status and key outputs, while the Chief Advisor reported on the successful completion of the third round of Training of Trainers (ToT) for INSET in BTB and KC. Provincial representatives shared their upcoming INSET plans, and the MoH officers introduced the progress and future direction of the e-learning platform.

A potential plan to expand the ToT program to other provinces was also shared, and participants exchanged views on future possibilities, remaining challenges, and areas for further coordination. While recognizing that additional efforts will be required to move forward, the meeting concluded with a strong sense of shared commitment to strengthening the INSET system for nurses and continuing close collaboration among all stakeholders toward achieving the Project's objectives.



Active Discussion
During the Meeting



Participants of the JCC meeting

## Orientation Meeting for PTMT in BTB

On 31st July 2025, an orientation meeting for Battambang (BTB) Provincial Training Management Team (PTMT) was held via Zoom, attended by the PHD Director, all nine PTMT members, and the technical team of the Project. The meeting marked the first step in handing over tasks from the Project to the province for organizing the upcoming In-service Training (INSET) scheduled to start in September 2025.

The Project provided an overview of the PTMT's roles and responsibilities based on the Terms of Reference, followed by an active discussion to confirm procedures and responsibilities related to INSET implementation. Key points included identifying focal persons for CCN registration and e-learning platform support, as well as confirming tentative dates for three training courses to be conducted in two Operational Districts (ODs) located in remote areas of the province.

The PTMT raised several operational questions regarding reporting responsibilities, certificate issuance, official correspondence formats, and pre/post-test administration. The Project team responded to these inquiries and clarified that while technical support will continue during the upcoming training, PTMT members are expected to gradually take on more responsibility.

This meeting reaffirmed the PTMT's central role in managing INSET activities in the province and contributed to strengthening their ownership and operational readiness.



Meeting with BTB PTMT

**UPCOMING ACTIVITIES IN AUGUST**

- 7th : Monthly Meeting with JICA HQ / Cambodia Office


**CONTACT INFORMATION**

Scan here to find out more about us:

JICA's FB Page

Project's Homepage

**Email**: info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

# Monthly Report Volume 43

កក្កដា ២០២៥

## សកម្មភាពគម្រោងប្រចាំខែកក្កដា៖

- ថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដា៖ អនុវត្តន៍ការវាយតម្លៃលើក្រោយការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ
- ថ្ងៃទី១០៖ ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្តាល JICA និង ការិយាល័យ JICA នៅប្រទេសកម្ពុជា
- ថ្ងៃទី១៦៖ កិច្ចប្រជុំលើកទី៦ នៃគណៈកម្មការសម្របសម្រួល (6th JCC)
- ថ្ងៃទី៣១៖ ការប្រជុំតម្រង់ទិសសម្រាប់ក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលខេត្តបាត់ដំបង (BTB-PTMT)

## កិច្ចប្រជុំលើកទី៦ នៃគណៈកម្មការសម្របសម្រួល នៅក្រសួងសុខាភិបាល

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ កិច្ចប្រជុំលើកទី៦ នៃគណៈកម្មការសម្របសម្រួលគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារ នៅប្រទេសកម្ពុជាក្រោមកិច្ចសហប្រតិបត្តិការ រវាងក្រសួងសុខាភិបាល និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA)។ កិច្ចប្រជុំនេះដឹកនាំដោយ ឯកឧត្តមសាស្ត្រាចារ្យ ជា គ្រុយ រដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល និងជានាយកគម្រោង និងមានការអញ្ជើញចូលរួមពី ភាគីពាក់ព័ន្ធសំខាន់ៗរួមមាន តំណាងមកពីក្រសួងសុខាភិបាល, JICA, ស្ថានទូតជប៉ុន និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។

កិច្ចប្រជុំបានផ្តល់ឱកាសដ៏មានតម្លៃដើម្បីពិនិត្យមើលវឌ្ឍនភាពដែលបានធ្វើឡើងនៅចន្លោះខែធ្នូ ឆ្នាំ២០២៤ ដល់ខែមិថុនា ឆ្នាំ២០២៥ និងដើម្បីពិភាក្សាអំពីផែនការសកម្មភាពសម្រាប់ប្រាំមួយខែខាងមុខ។ លោកស្រីសាស្ត្រាចារ្យជំ. ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងជាប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង បានបង្ហាញពីទិដ្ឋភាពទូទៅនៃស្ថានភាពការអនុវត្ត និងលទ្ធផលសំខាន់ៗ របស់គម្រោង។ ជាមួយគ្នានោះដែរលោកស្រីបណ្ឌិត Yoko Yamamoto ប្រធានទីប្រឹក្សាគម្រោង បានរាយការណ៍អំពីការបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលវគ្គ៣ (ToT-3) ដោយជោគជ័យ សម្រាប់ធ្វើការបណ្តុះបណ្តាលក្នុងពេលបម្រើការងារ(INSET) ដល់គិលានុបដ្ឋាក នៅខេត្តកំពង់ចាម និងខេត្តបាត់ដំបង។ តំណាងខេត្តទាំងពីរ បានបង្ហាញអំពីផែនការ INSET នាពេលខាងមុខរបស់ពួកគេ ហើយមន្ត្រីក្រសួងសុខាភិបាលបានជម្រាបជូនពីវឌ្ឍនភាព និងទិសដៅអនាគត នៃវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (e-learning platform)។

ផែនការបន្ទាប់ ក្នុងការពង្រីកកម្មវិធីវគ្គបណ្តុះបណ្តាលគ្រូបង្គោល (ToT) ទៅកាន់ខេត្តផ្សេងទៀត ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ហើយអ្នកចូលរួមទាំងអស់ បានផ្លាស់ប្តូរមតិយោបល់អំពីលទ្ធភាពនាពេលអនាគត បញ្ហាប្រឈមដែលនៅសល់ និងទីកន្លែងសម្រាប់ការសម្របសម្រួលបន្ថែមទៀត។ ការងារទាំងអស់នេះទៀមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីឆ្ពោះទៅមុខ។ កិច្ចប្រជុំបានបញ្ចប់ដោយការប្តេជ្ញាចិត្តយ៉ាងមុតមាំរួមគ្នាក្នុងការពង្រឹងប្រព័ន្ធការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) និងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដើម្បីឈានទៅរកការសម្រេចបាននូវគោលបំណងរួមរបស់គម្រោង។




Active Discussion During the Meeting



Participants of the JCC meeting

## ការប្រជុំតម្រង់ទិសសម្រាប់ក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាល ខេត្តបាត់ដំបង (BTB-PTMT)

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ កិច្ចប្រជុំតម្រង់ទិសសម្រាប់ក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលខេត្តបាត់ដំបង (BTB-PTMT) ត្រូវបានធ្វើឡើងតាមរយៈ Zoom ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមប្រធាន មន្ទីរសុខាភិបាលខេត្ត និងសមាជិក PTMT ទាំងប្រាំបួនរូប និងក្រុមការងារបច្ចេកទេសគម្រោង។ កិច្ចប្រជុំបានកត់សម្គាល់ជំហានដំបូងក្នុងការប្រគល់ភារៈកិច្ចពីគម្រោងទៅក្រុមការងារថ្នាក់ខេត្តក្នុងការរៀបចំវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ដែលគ្រោងនឹងចាប់ផ្តើមនៅខែកញ្ញា ឆ្នាំ២០២៥ ខាងមុខនេះនៅខេត្តបាត់ដំបង។

គម្រោងបានបង្ហាញទិដ្ឋភាពទូទៅនៃតួនាទី និងទំនួលខុសត្រូវរបស់ក្រុម PTMT ដោយផ្អែកលើលក្ខខណ្ឌនៃតួនាទីភារកិច្ច (TOR)។ បន្ទាប់មកមានការពិភាក្សាយ៉ាងសកម្មដើម្បីបញ្ជាក់អំពីនីតិវិធី និងទំនួលខុសត្រូវទាក់ទងនឹងការអនុវត្ត INSET ។ ចំណុចសំខាន់ៗក្នុងកិច្ចប្រជុំនេះរួមមាន៖ ការកំណត់មន្ត្រីដែលទទួលបន្ទុកសម្រាប់ការចុះឈ្មោះនៅគណៈគិលានុបដ្ឋាកកម្ពុជា (CCN) និងការជួយសម្របសម្រួល e-learning platform ក៏ដូចជាការបញ្ជាក់ពីកាលបរិច្ឆេទបណ្តោះអាសន្នសម្រាប់វគ្គបណ្តុះបណ្តាលចំនួនបីទៀត ដែលនឹងត្រូវធ្វើឡើងនៅក្នុងស្រុកប្រតិបត្តិ (ODs) ចំនួនពីរ ដែលមានទីតាំងនៅតំបន់ដាច់ស្រយាលពីទីរួមខេត្ត។

ក្រុម PTMT បានលើកឡើងនូវសំណួរមួយចំនួនទាក់ទងទៅនឹង អ្នកទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ អ្នកទទួលបន្ទុកចេញវិញ្ញាបនបត្រ ទម្រង់ការឆ្លើយឆ្លងផ្លូវការ និងការគ្រប់គ្រងការធ្វើតេស្តមុន និងតេស្តក្រោយវគ្គសិក្សា។ ក្រុមការងារគម្រោងបានឆ្លើយតបទៅនឹងសំណួរទាំងនេះ ហើយបានពន្យល់ថា គម្រោងនឹងគាំទ្រផ្នែកបច្ចេកទេសក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនាពេលខាងមុខ ហើយសមាជិក្រុម PTMT ត្រូវបានរំពឹងថានឹងទទួលខុសត្រូវជាបណ្តើរៗបន្ថែមទៀត។

កិច្ចប្រជុំនេះបានបញ្ជាក់ពីតួនាទីស្នូលរបស់ក្រុម PTMT ក្នុងការគ្រប់គ្រងសកម្មភាព INSET នៅក្នុងខេត្ត និងបានរួមចំណែកក្នុងការពង្រឹងភាពជាម្ចាស់ និងការត្រៀមខ្លួនក្នុងការអនុវត្តរបស់ពួកគេ។




Meeting with BTB PTMT

## សកម្មភាពនាពេលខាងមុខក្នុងខែសីហា

- ថ្ងៃទី៧៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office


**CONTACT INFORMATION**

Scan here to find out more about us:

JICA's FB Page

Project's Homepage

**Email**: info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork,  Daun Penh District, Phnom Penh